00647334

E55

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត: សាធារណៈ / Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ អៀង ធីរិទ្ធ, អៀង សារី និង នួន ជា សុំប្តឹងជំទាស់ចៅក្រម

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:

លោកស្រី ជា លាង

លោក Andrew CAYLEY

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:

ពេជ អង្គ

Elisabeth SIMONNEAU FORT

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:

ចៅក្រម និល ណុន, ប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រមJean-Marc LAVERGNE

ចៅក្រម ធូ មណី

**ចម្លងជូន:**

ជនជាប់ចោទ:

នួន ជា

អៀង សារី

អៀង ធីរិទ្ធ

ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor Koppe

លោក អាង ឧត្តម

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU

ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception):
23 / 02 / 2011

ម៉ោង (Time/Heure): 15:55

មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

00647335

E55

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសង*

លោក Michael G.KARNAVAS
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC
លោក សរ សូវាន
លោក Jacques VERGÈS
លោក Phillipe GRECIANO

## សេចក្តីផ្តើម

១. នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១១ មេធាវីការពារក្តី អៀង ធីរិទ្ធ បានដាក់សំណើ ("សំណើរបស់ អៀង ធីរិទ្ធ") សុំប្តឹងជំទាស់ចំពោះចៅក្រម និល ណុន, Silvia CARTWRIGHT, យ៉ា សុខន, Jean-Marc LAVERGNE និង ធូ មណី[1] ("ចៅក្រម") ។ សំណៅចម្លងនៃសំណើ ស្រដៀងគ្នា នេះ ត្រូវបានជូនដំណឹងដល់ភាគីនានាតែមួយភាសាតាមអ៊ីមែលក្នុងនាម អៀង សារី[2] និង នួន ជា (សំណើរបស់ អៀង សារី និង សំណើរបស់ នួន ជា រៀងៗខ្លួន)[3] ។ ដោយមានការកត់សម្គាល់ទៅលើអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ថាជានីតិវិធីបណ្តោះអាសន្ន នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង កាលណាការរាំងស្ទះក្នុងការបកប្រែធ្វើឱ្យ ភាគីនានាអាក់ខានក្នុងការអនុវត្តតាមកាលបរិច្ឆេទកំណត់ក្នុងការដាក់ឯកសារ[4] និងនៅក្នុងផលប្រយោជន៍នៃដំណើរការនីតិវិធីដ៏ឆាប់រហ័សនោះចម្លើយតបរួមនេះនឹងធ្វើការលើកឡើងពីសំណើរបស់ អៀង ធីរិទ្ធ, សំណើរបស់ អៀង សារី និងសំណើរបស់ នួន ជា (ទាំងអស់នេះ "សំណើរួម")។ សំណើនេះ ស្នើថា ចៅក្រមដែលបានបង្កើតនៅក្នុងអង្គជំនុំជម្រះសាលាដំបូងនេះគួរតែត្រូវបានប្តឹងជំទាស់ឱ្យចាកចេញពីការវិនិច្ឆ័យសេចក្តីលើជនជាប់ចោទនៅក្នុងសវនាការខាងមុខនេះ។ ដូចមានហេតុផលទាំងឡាយនៅខាងក្រោមនេះ សហព្រះរាជអាជ្ញា សូមជំទាស់ទៅនឹងសំណើនេះ។

---

[1] ករណីរបស់ អៀង ធីរិទ្ធ, ០០២/១៩-០៩-២០០៧-អវតក/អជសដ, សំណើរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ សុំប្តឹងជំទាស់ចំពោះចៅក្រម និល ណុន, Silvia CARTWRIGHT, យ៉ា សុខន, Jean-Marc LAVERGNE និង ធូ មណី, ថ្ងៃទី១ កុម្ភៈ ២០១១, E28 ERN: 00641075-00641090 ។

[2] ករណីរបស់ អៀង សារី, ០០២/១៩-០៩-២០០៧-អវតក/អជសដ, ញត្តិរបស់មេធាវីការពារក្តី អៀង សារី គាំទ្រសំណើរបស់ អៀង ធីរិទ្ធ និង នួន ជា សុំប្តឹងជំទាស់ចំពោះចៅក្រមអង្គជំនុំជម្រះសាលាដំបូង និងញត្តិរបស់ អៀង សារី ចូលរួមនឹងសំណើរបស់របស់ អៀង ធីរិទ្ធ សុំឱ្យផ្លាស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង - សម្រាប់គោលបំណងធ្វើការវិនិច្ឆ័យលើសំណើ - ដោយចៅក្រមបំរុងនៃអង្គជំនុំជម្រះសាលាដំបូង ឬ ចៅក្រមបន្ថែមជ្រើសរើសដោយគណៈកម្មការរដ្ឋបាលតុលាការ, ថ្ងៃទី១៧ កុម្ភៈ ២០១១ ។ សំណើទាំងពីរនេះ ត្រូវបានបញ្ជូនដោយមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ។

[3] ករណីរបស់ នួន ជា, ០០២/១៩-០៩-២០០៧-អវតក/អជសដ, សំណើបន្ទាន់របស់មេធាវីការពារក្តី នួន ជា សុំប្តឹងជំទាស់ចំពោះចៅក្រមអង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី៨ កុម្ភៈ ២០១១ ។

[4] ឯកសារលេខ E38, ERN 00643388, ថ្ងៃទី៨ កុម្ភៈ ២០១១ ។

00647337



២. មេធាវីការពារក្តី បានលើកសំអាងថា ការរកឃើញពី អង្គហេតុ និងអង្គច្បាប់ដែលអង្គជំនុំជម្រះសាលាដំបូងបានសរសេរក្នុងសាលក្រម នៅក្នុងករណីរឿងរបស់*ឌុច*[5] គឺជាអ្វីដូចដែលអ្នកសង្កេតការណ៍ប្រកបដោយវិចារណញ្ញាណម្នាក់ ដែលត្រូវបានជម្រាបយ៉ាងត្រឹមត្រូវឱ្យបានដឹងនូវ ព័ត៌មាននោះមុខជានឹងយល់តាមដោយផ្អៀងទៅខាងចៅក្រមជាមិនខាន។ ជាលទ្ធផលពួក គេលើកសំអាងថា ចៅក្រមគួរតែត្រូវបានប្តឹងជំទាស់ ដោយអនុលោមតាមមាត្រា៣៤ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញនេះ។ សហព្រះរាជអាជ្ញា សន្និដ្ឋានថា កម្រិតខ្ពស់ ឬទាបបំផុតក្នុងការកំណត់ពីភាពលេចឡើងនូវសេចក្តីលំអៀង វាមិនត្រូវទៅតាមនោះទេ ហើយថា បើយ៉ាងដូច្នេះ សំណើទាំងនេះគួរតែត្រូវបានបដិសេធចោល។

## ការពិសោធន៍សាកល្បងលើភាពអនាគតិ

៣. សហព្រះរាជអាជ្ញា សន្និដ្ឋានថា ភាពអនាគតិរបស់តុលាការគឺជាប់ទាក់ទងទៅនឹងដំណើរការ តែមិនមានទាក់ទងទៅនឹងលទ្ធផលទេ។ ការណ៍នេះគឺមានជាប់ជាមួយនឹងសញ្ញាណនៃការលំអៀង ដែលគេបានផ្តល់និយមន័យថាជា "*ការលំអៀងរបស់ចៅក្រមណាមួយចំពោះភាគីណាមួយ ឬច្រើនក្នុងចំណោមភាគីទាំងឡាយនៅក្នុងករណីរឿងណាមួយដែលចៅក្រមរូបនោះធ្វើជាអធិបតី*[6]" ហើយ ដែលតុលាការជាន់ខ្ពស់នៃប្រទេសអូស្រ្តាលី បានចែងយ៉ាងច្បាស់លាស់ថា៖

"វាត្រូវការឱ្យនិយាយខ្លាំងៗ និងច្បាស់ៗថា ទង្វើករណីនៃការប្តឹងជំទាស់គឺជាការចាប់បានដ៏សមហេតុផលមួយ ដែលថាមន្ត្រីតុលាការនឹងមិនធ្វើការសម្រេចលើករណីរឿងដោយភាពអនាគតិ ឬដោយគ្មានបុរេវិនិច្ឆ័យ ជាជាងការដែលថាគាត់នឹងធ្វើការសម្រេចលើករណីរឿងដោយជាសត្រូវទៅនឹងភាគីមួយទៀត"[7] ។

---

[5] សាលក្រម, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី២៦ កក្កដា ២០១០, E188, កថាខណ្ឌទី ៤៤, ៤៥, ៩០, ១៣១ និង ៥០៩ ។

[6] វចនានុក្រម Black"s Law, បោះពុម្ពលើកទី៨, ឆ្នាំ២០០៤, រោងពុម្ព West, សហរដ្ឋអាមេរិក, ទំព័រ១៧១ ។

[7] *Re: JRL; ex parte CJL* (1986) 161 CRL.

សេចក្តីដកស្រង់នេះត្រូវបានគេដាក់ក្នុងអញ្ញប្រកាសដោយមានការយល់ព្រមពី, *ក្នុងចំណោមទាំងអស់នោះ (inter alia),* តុលាការរដ្ឋធម្មនុញ្ញអាហ្វ្រិកខាងត្បូង[8], តុលាការ ICTR នៅក្នុងករណីរបស់ *Karemera*[9], និងតុលាការ ICTY នៅក្នុងករណីរបស់ *Brdjanin and Talic*[10] និង *Celebici*[11]។ នៅក្នុងករណីរបស់ *Karemera* តុលាការ ICTR បានបង្កើតគោលការណ៍នៃភាពអនាគតិបន្ថែមនៅក្នុងនីតិវិធីក្រោយជាបន្តទៀត ដោយថ្លែងថា៖

> ... អ្វីដែលត្រូវតែបានបង្ហាញ នោះគឺថាសេចក្តីសម្រេចនានាគឺជាការអាចសន្និតបាន ឬត្រូវបានមើលឃើញថាជាសេចក្តីលំអៀងមួយប្រឆាំងនឹងអ្នកដាក់សំណើ និងមិនពាក់ព័ន្ធដោយពិតប្រាកដទៅនឹងការអនុវត្តច្បាប់ដែលគេអាចមានលទ្ធភាពធ្វើការបកស្រាយបានច្រើនយ៉ាង ឬមិនពាក់ព័ន្ធដោយពិតប្រាកដទៅនឹងការវាយតម្លៃ[12] ។

ដូច្នេះ *លក្ខខណ្ឌចាំបាច់* *(conditio sine qua non)* ក្នុងការបង្កើតកង្វះខាតនូវភាពអនាគតិនោះគឺការផ្តល់ភស្តុតាងថាចៅក្រមបានបង្ហាញសេចក្តីលំអៀងមួយដែលមិនត្រូវកន្លែងឬដែលមិនត្រឹមត្រូវប្រឆាំងនឹងជនចាប់ចោទ ដែលមិនជាប់ទាក់ទងដោយពិតប្រាកដទៅនឹងការអនុវត្តច្បាប់[13] ។ អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញា សន្និដ្ឋានថា នៅក្នុងវិសាលភាពដែលមេធាវីការពារក្តី អៀង សារី លើកសំអាងថា អង្គជំនុំជម្រះសាលាដំបូងមិនទំនងជាសម្រេចលើករណីរឿងផ្សេងៗពីគ្នានោះ សំណើរបស់ពួកគេស្តែងចេញមកដោយមិនមានមូលដ្ឋានត្រឹមត្រូវទៅតាមច្បាប់ទេ ។

---

8 *សហព័ន្ធកីឡាបាល់រូប៊ីអាហ្វ្រិកខាងត្បូង,* តុលាការរដ្ឋធម្មនុញ្ញអាហ្វ្រិកខាងត្បូង, សំណុំរឿង CCT 16/98, ថ្ងៃទី៤ មិថុនា ១៩៩៩, កថាខណ្ឌទី ៤៦ ។

9 *រដ្ឋអាជ្ញា ទល់នឹង Karemera និងគូកន,* ICTR -98-44-T, សេចក្តីសម្រេចលើញត្តិដាក់ដោយ Karemera សុំប្តឹងជំទាស់ចិត្តចំពោះចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី១៧ ឧសភា ២០០៤, ត្រង់កថាខណ្ឌទី ១០ ។

10 *រដ្ឋអាជ្ញា ទល់នឹង Brđanin និង Talić,* ICTY-99-36, សេចក្តីសម្រេចលើសំណើដាក់ដោយ Momir Talić សុំប្តឹងជំទាស់ចិត្ត និងសុំការដកខ្លួនចៅក្រមមួយរូប, កថាខណ្ឌទី ១៨ ។

11 *រដ្ឋអាជ្ញា ទល់នឹង Delalic, Mucic, Hazim និង Landzo* ("ករណីរបស់ Celebici") IT-96-21-A, សាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ថ្ងៃទី២០ កុម្ភៈ ២០០១, កថាខណ្ឌទី ៧០៧ ។

12 *រដ្ឋអាជ្ញា ទល់នឹង Karemera និងគូកន,* ICTR -98-44-T, សេចក្តីសម្រេចលើញត្តិដាក់ដោយ Karemera សុំប្តឹងជំទាស់ចិត្តចំពោះចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី១៧ ឧសភា ២០០៤, កថាខណ្ឌទី ១៣ ។

13 សូមមើលផងដែរ ការកត់សម្គាល់លើវចនានុក្រម Black"s Law, ខាងលើ, ទំព័រទី ១៧ ។

## ភាពអនាគតិដូចដែលបានអនុវត្តចំពោះច្បាប់ព្រហ្មទណ្ឌអន្តរជាតិ

៤. នៅក្នុងករណីបច្ចុប្បន្ននេះ ក្រុមមេធាវីការពារក្តីនានាមិនបានលើកសំអាងថា សាលក្រមរបស់ ឌុច បានបង្ហាញថាចៅក្រមយកមកពិចារណានូវកត្តានានាដែលមិនត្រូវកន្លែង ឬដែលមិនត្រឹមត្រូវ ទេ។ ពួកគេបានលើកសំអាងថា សេចក្តីសម្រេចនេះបានបង្ហាញថាចៅក្រមបានធ្វើការកំណត់តាមផ្លូវតុលាការនូវទិដ្ឋភាពជាក់លាក់មួយចំនួនក្នុងករណីទាំងនេះប្រឆាំងនឹង អៀង ធីរិទ្ធ, អៀង សារី និង នួន ជា ទាំងអស់នេះ (“ជនជាប់”)។ នៅក្នុងហេតុផលនេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា វាជាបញ្ហាមួយពិតមែនហើយ ជាពិសេសនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលថាជាញឹកញាប់ចៅក្រមនឹងត្រូវបានតម្រូវឱ្យធ្វើការកំណត់លើបញ្ហានានា ក្នុងករណីរឿងផ្សេងៗគ្នា ដោយមានទទ្បីករណ៍ឈរនៅលើកម្រងអង្គហេតុដូចៗគ្នា ឬស្រដៀងគ្នា។ វាគឺជាគោលការណ៍មួយដែលបានបង្កើតឡើងយ៉ាងត្រឹមត្រូវ ដែលគេសន្មតថាចៅក្រមអាចមានលទ្ធភាពនៅក្នុងការទុកដាក់ដោយឡែកនូវកត្តានានាបែបនេះ និងនៅក្នុងការកំណត់លើករណីនីមួយៗទៅតាមអង្គសេចក្តីរបស់វាផ្ទាល់។ ការណ៍នេះត្រូវបានតុលាការ ICTY យកទៅសម្រេច នៅក្នុងករណីរបស់ *Galić* ដែលគេបានថ្លែងថា៖

“ការបណ្តុះបណ្តាលនិងបទពិសោធន៍វិជ្ជាជីវៈរបស់ចៅក្រមគឺពួកគេបានជ្រួតជ្រាបពីសមត្ថភាពក្នុងការបញ្ចេញភស្តុតាងនៃគំនិតជាជាងពីអ្វី ដែលបានដាក់បង្ហាញនៅពេលសវនាការនៅក្នុងការចេញជាសាលក្រមមួយ[14]”។

គោលការណ៍នេះ ត្រូវបានធ្វើឡើងវិញម្តងទៀតដោយតុលាការ ICTY នៅក្នុងករណីរបស់ *Celebici*[15] និងតុលាការ ICTR នៅក្នុងករណីរបស់ *Karera*[16], *Nahimana* និងគូកន[17] ហើយនិង *Ntawukulilyayo*[18] ។ អានុភាពនៃការសន្មតទុកជាមុននេះ គឺថា “...វាមិនទៅតាមអ្វីដែល

---

14 *រដ្ឋអាជ្ញា ទល់នឹង Galić*, IT-98-29-A, សាលដីកា, ថ្ងៃទី៣០ វិច្ឆិកា ២០០៦, កថាខណ្ឌទី ៤៤ ។

15 *រដ្ឋអាជ្ញា ទល់នឹង Delalic, Mucic, Hazim និង Landzo* (“ករណីរបស់ Celebici”) IT-96-21-A, សាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ថ្ងៃទី២០ កុម្ភៈ ២០០១, កថាខណ្ឌទី ៧០០ ។

16 *François Karera ទល់នឹង រដ្ឋអាជ្ញា*, ICTR-07-74-A, សាលដីកា, ថ្ងៃទី២ កុម្ភៈ ២០០៩, កថាខណ្ឌទី ៣៧៨ ។

17 *Nahimana និងគូកន ទល់នឹង រដ្ឋអាជ្ញា*, ICTR-99-52-A, សាលដីកា, ថ្ងៃទី២៨ វិច្ឆិកា ២០០៧, កថាខណ្ឌទី ៧៨ ។

18 *Ntawukulilyayo ទល់នឹង រដ្ឋអាជ្ញា*, ICTR-05-82-A, សេចក្តីសម្រេចលើញត្តិស្នើសុំប្តឹងជំទាស់ចំពោះពួកចៅក្រម, ថ្ងៃទី៨ កុម្ភៈ ២០១១, កថាខណ្ឌទី ១២, ដោយបានស្រង់សំដីរបស់ *Karera* ។

00647340



ចៅក្រមណាម្នាក់ ត្រូវបានប្តឹងជំទាស់ដោយសារបើកធ្វើសវនាការលើរឿងក្តីព្រហ្មទណ្ឌចំនួនពីរ ឬច្រើនដែលកើតចេញពីព្រឹត្តិការណ៍ដូចៗគ្នា ខណៈដែលគាត់ត្រូវបានគេដាក់ភស្តុតាងពាក់ព័ន្ធនឹងព្រឹត្តិការណ៍ក្នុងករណីរឿងទាំងពីរនេះ[19]" ។

ស្រដៀងគ្នានេះដែរ សេចក្តីសម្រេចនានាត្រូវបានធ្វើឡើងនៅក្នុងករណីរបស់ *Karadzic*[20], *Ntawukulilyayo*[21] និងក្នុងករណីរបស់ *Brđanin* និង *Talić*[22] ។

៥. គោលការណ៍គឺនៅតែល្អដដែលទោះបី បើសិនជាបញ្ហាត្រូវបានចាត់ទុកដោយក្រុមចៅក្រមនៅក្នុងសវនាការជំនុំជម្រះក្តី ឬសាលក្រមពីមុនថាជាបញ្ហាស្នូលមួយនៃសំណុំរឿងបច្ចុប្បន្ននេះក្តី។ ដូច្នេះជាឧទាហរណ៍នៅក្នុងករណី *Lindon*[23] ដែលមានករណីបង្ខូចកេរ្តិ៍ឈ្មោះពីឬករណីជាបទព្រហ្មទណ្ឌបានកើត ឡើងតុលាការ ECtHR បានសម្រេចថា ការរកឃើញមួយដោយចៅក្រមពីររូបនៅក្នុងករណីទីមួយដែលថាសម្រង់ ឯកសារមានលក្ខណៈបង្ខូចកេរ្តិ៍ឈ្មោះ គឺមិនគ្រប់គ្រាន់ដើម្បីបង្ហាញឲ្យឃើញពិតប្រាកដពីកង្វះ ខាតភាពមិនលំអៀងដោយចៅក្រមពីររូបដដែលនោះដែលអង្គុយជាមួយនឹងចៅក្រមដទៃទៀតនៅ ករណីទីពីរ។ បញ្ហាដែលថាតើអ្នកដាក់ពាក្យសុំបានធ្វើដោយអំពើសុទ្ធចិត្ត ឬអសុទ្ធចិត្ត គឺនៅតែបើកចំហរនៅក្នុងករណីទីពីរ និងមិនបានធ្វើឲ្យខូចដោយសារតែ សាលក្រមទីមួយទេ។ ការសម្រេចនៅក្នុងករណីទីមួយមិនមែនជាការសម្រេចអំពីពិរុទ្ធភាពរបស់ អ្នកដាក់ពាក្យសុំក្នុងករណីទីពីរនេះទេ ដូច្នេះទើបមិនមានការរកឃើញនូវភាពលំអៀង[24]។ គោលការណ៍នេះត្រូវបានដាក់បញ្ចូលនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ តាម

---

19 *រដ្ឋអាជ្ញា ទល់នឹង Kordić and Čerkez,* IT-95-14/2-PT, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីស្នើសុំប្តឹងជំទាស់ចំពោះចៅក្រម Jorda និង Riad, ថ្ងៃទី៤ ឧសភា ១៩៩៨, ទំព័រទី ២ ។

20 *រដ្ឋអាជ្ញា ទល់នឹង Karadzic*, IT-95-05/18-PT, សេចក្តីសម្រេចដោយអង្គជំនុំជម្រះដែលបានកោះហៅប្រជុំដោយដីការបស់អនុប្រធាន, ថ្ងៃទី២២ កក្កដា ២០០៩, កថាខណ្ឌទី ២២ ។

21 *Ntawukulilyayo*, កថាខណ្ឌទី ១២ ។

22 *Talić*, កថាខណ្ឌទី ១៦ ។

23 ករណីរឿក្តីរបស់ *Lindon Otchakovsky-Laurens និង July ទល់នឹង ប្រទេសបារាំង,* តុលាការ ECHR [GC], សំណុំរឿងលេខ 21279/02 និង 26448/02, សេចក្តីសម្រេច ចុះថ្ងៃទី២២ តុលា ២០០៧, កថាខណ្ឌទី៧៩។

24 ក្នុងករណី Lindon, ECtHR បានកត់សំគាល់ឃើញថា ការសម្រេចពីមុនទៅលើឯកសារអនុម័តដែលមានលក្ខណៈបង្ខូចឈ្មោះ ត្រូវជាប់កាតព្វកិច្ចនៅក្រោមគោលការណ៍*អាជ្ញាអស់ជំនុំ* ។ សហព្រះរាជអាជ្ញាមិនមែនតវ៉ាថា គោលការណ៍នៃ*អាជ្ញាអស់ជំនុំ* អនុវត្តបានបញ្ហាបច្ចុប្បន្នទេ ប៉ុន្តែអ្វីដែល Lindon បង្ហាញឲ្យឃើញនោះគឺថា ទោះបីជាការសម្រេចពីមុនមានលក្ខណៈជាប់កាតព្វកិច្ចក៏ដោយ ក៏គេមិនអាចបង្កើតបាននូវការប្រាកដខ្លួនឡើងនៃភាពលំអៀងដែរ ប្រសិនបើគេមិនបានកំណត់ជាមុនអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។

របៈករណីរឿងក្តីមួយចំនួន ដែលក្នុងនោះមាន ករណីរឿងក្តីរបស់ *Brđanin* និង *Talić*[25] ដែល ជាប់ទាក់ទងទៅនឹងការរកឃើញកាលពីមុនអំពីអត្ថិភាពនៃ "ជម្លោះប្រដាប់អាវុធអន្តរជាតិ" មួយ, ករណីរឿក្តីរបស់ *Karadizić*[26] និង *Ntawukulilyayo*[27] ។ ទោះបីជានៅក្នុងពាក្យសុំរបស់ អៀង ធីរិទ្ធ បានពោលអះអាងដោយមិនត្រឹមត្រូវថា បញ្ហាស្តីពីជម្លោះប្រដាប់អាវុធអន្តរជាតិ មិនអាចតវ៉ាជំទាស់ដោយ មេធាវីការពារក្តី [unchallenged] នៅក្នុងករណីរឿងរបស់ ឌុច នោះ ក៏ដោយក៏ ដូចដែលអាចឃើញស្រាប់នៅក្នុងករណីទាំងឡាយខាងលើនេះ ការតវ៉ាជំទាស់បែប នេះគឺមិនមែនជាការសំខាន់ចាំបាច់ជាសារវន្ត ដើម្បីធានាចំពោះភាពមិនលំអៀងរបស់ចៅក្រមនៅ ក្នុងករណីរឿងក្រោយនេះឡើយ[28]។ ហេតុដូចនេះ ទោះបីជាត្រូវបានទទួលការយល់ព្រមថា សាលក្រមករណីរឿង ឌុច បង្ហាញភស្តុតាងអំពី "លក្ខខណ្ឌតម្រូវជាមុនដែលគ្របដណ្តប់សព្វ គ្រប់ទាំងអស់ [*Chapeau* prerequisites]" សម្រាប់ឧក្រិដ្ឋកម្មផ្សេងៗនោះក៏ដោយក៏ វាមិនគ្រប់ គ្រាន់សម្រាប់បង្ហាញ ភស្តុតាងឲ្យឃើញថាគ្មានភាពមិនលំអៀង ពីសំណាក់ចៅក្រមនានានោះ ដែរ។

៦. ដើម្បីឲ្យសាលក្រម ឬសេចក្តីសម្រេចពីមុនៗណាមួយអាចមានលទ្ធភាពក្នុងការបង្ហាញឲ្យឃើញ ថាមានភាពលំអៀងណាមួយ តាមរបៀបដូចដែលមេធាវីបានលើកជាទឡ្ហីករណ៍នោះ គឺភាព លំអៀងនោះចាំបាច់តោងតែ "....ដោយផ្ទាល់ ឬតាមការទាញសេចក្តីសន្និដ្ឋាន បង្កើតបានជា ការរកឃើញនានាស្តីពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាលក្ខណៈបុគ្គល..."[29] របស់ជនជាប់ ចោទ។ គោលការណ៍នេះត្រូវបានបញ្ជាក់ដោយខ្លីៗនិងច្បាស់ៗដោយតុលាការ ECHR ដែលមាន ចែងនៅក្នុងករណីរឿងរបស់ *Poppe* ថាៈ

[25] ករណីរឿងក្តីរបស់ *Talić*, កថាខណ្ឌទី១៦។

[26] ករណីរឿងក្តីរបស់ *Karadzic*, កថាខណ្ឌទី២៣។

[27] ករណីរឿងក្តីរបស់ Ntawukulilyayo, កថាខណ្ឌទី១២។

[28] សូមអាន *ប្រតិចារិកនៃសវនាការជំនុំជម្រះក្តីរឿងរបស់ ឌុច*, ចុះថ្ងៃទី២១ ឧសភា ២០០៩, ត្រង់ទំព័រ១៣ ដែលលោកចៅក្រម Cartwright និយាយទៅកាន់សហព្រះរាជអាជ្ញាថា "ទាក់ទងនឹងបញ្ហាដែលលោកបានលើកឡើង អំពីជម្លោះប្រដាប់អាវុធនោះ ខ្ញុំទទួលស្គាល់បញ្ហាហើយ។ ទីមួយ ជនជាប់ចោទ *មិនបានទទួលយល់ព្រមទាំងស្រុង* លើអង្គហេតុនៃជម្លោះប្រដាប់អាវុធនោះទេ ដែលហេតុដូចនេះត្រូវតែបង្ហាញភស្តុតាង។ *សូមអានផងដែរ* នូវសក្ខីកម្មរបស់អ្នកជំនាញ ណាយ៉ាន់ ចាន់ដា កាលពីថ្ងៃទី២៦ ឧសភា ២០០៩ ត្រង់ទំព័រពី៣៩ ដល់៤២ ដែលពេល នោះមេធាវីការពារក្តីបានប្រឆាំងជំទាស់នឹងអត្ថិភាពនៃជម្លោះប្រដាប់អាវុធ នៅមុនចុងឆ្នាំ១៩៧៧"។

[29] ករណីរឿងក្តីរបស់ *Karadzic*, កថាខណ្ឌទី២២។

ប្រការជាក់ស្តែងដែលគ្រាន់តែថា ចៅក្រមបាន...ជំនុំជម្រះក្តីសហជនជាប់ចោទរួចហើយនៅក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌដាច់ដោយឡែកតែប៉ុណ្ណោះ នោះគឺវាមិនគ្រប់គ្រាន់ដើម្បីធ្វើឱ្យមានការមន្ទិលសង្ស័យអំពីភាពមិនលំអៀងរបស់ចៅក្រមនៅក្នុងករណីរឿងក្តីក្រោយទៀតនោះទេ។ ប៉ុន្តែវាជាបញ្ហាមួយផ្សេងពីគ្នា បើសិនជានៅក្នុងសាលក្រមកាលពីមុនៗនោះមានការរកឃើញនានាដែលជាក់ស្តែងបណ្តាលឱ្យមានបុរេវិនិច្ឆ័យអំពីបញ្ហាពិរុទ្ធភាពរបស់ជនជាប់ចោទណាម្នាក់នៅក្នុងដំណើរការរឿងក្តីជាបន្តបន្ទាប់ពីនេះ[30]។

ហេតុនេះ បើសិនជារឿងក្តីដែលបានសម្រេចកាលពីមុន មិនបានកំណត់ទុកជាមុនអំពីពិរុទ្ធភាពរបស់បុគ្គលនៃជនជាប់ចោទ ដោយសារតែមិនបាននិយាយអំពីឧក្រិដ្ឋកម្មទាំងមូល ដូចជានៅក្នុងករណីរឿងក្តីរបស់ *Lindon*[31] ឬមួយក៏ដោយសារតែការកំណត់កាលពីមុននោះមិនបានបំពេញគ្រប់ទៅតាមបទដ្ឋានស្តីពីភស្តុតាងដែលតម្រូវដើម្បីសម្រេចក្តីឱ្យជនជាប់ចោទត្រូវមានទោស ដូចជានៅក្នុងករណីរឿងក្តីរបស់ *Karadzić*[32], *Ntawukulilyayo*[33] និង *Hauschildt*[34], ទេនោះ បន្ទាប់មកទៀត គឺវាមិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្ហាញភស្តុតាងឱ្យឃើញថា គ្មានភាពមិនលំអៀងនោះឡើយ។

## អំពីភាពមិនលំអៀង និងគោលការណ៍ស្តីពីសច្ចធារណ៍និរទោស

៧. សំណើរបស់ នួន ជា ខំព្យាយាមលើកឡើងនូវទឡ្ហីករណ៍ថា សាលក្រមករណី *ឌុច* គឺរំលោភយ៉ាងជាក់ស្តែងលើគោលការណ៍ស្តីពីសច្ចធារណ៍និរទោសដែលត្រូវអនុវត្តចំពោះរូបគាត់ ពីព្រោះវាមិនគ្រាន់ តែបង្ហាញភស្តុតាងឱ្យឃើញពី "លក្ខខណ្ឌតម្រូវដែលគ្របដណ្តប់សព្វគ្រប់ទាំងអស់" សម្រាប់ឧក្រិដ្ឋកម្មនានាតែប៉ុណ្ណោះនោះទេ ក៏ប៉ុន្តែថែមទាំងនិយាយដល់ពិរុទ្ធភាព បុគ្គលរបស់គាត់

---

[30] ករណីរឿងក្តីរបស់ *Poppe ទល់នឹង ប្រទេសហូឡង់*, តុលាការ ECHR, សំណុំរឿងលេខ 32271/04, សាលក្រម ចុះថ្ងៃទី ២៤ មិនា ២០០៨, កថាខណ្ឌទី២៦។

[31] ដូចគ្នានឹងខាងលើ។

[32] ករណីរឿងក្តីរបស់ *Karadzić*, កថាខណ្ឌទី២២។

[33] ករណីរឿងក្តីរបស់ *Ntawukulilyayo*, កថាខណ្ឌទី១២។

[34] ករណីរឿងក្តីរបស់ *Hauschildt ទល់នឹង ប្រទេសដាណឺម៉ាក*, តុលាការ ECHR សំណុំរឿងលេខ 10486/83, សាលក្រមចុះថ្ងៃទី២៤ ឧសភា ១៩៨៩។

តាមរយៈការរកឃើញនានាដូចជា អំពីតួនាទីនៃបុគ្គលរបស់គាត់នៅក្នុងបកក និងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទៀតផង។ សហព្រះរាជអាជ្ញា សូមបដិសេធនូវសេចក្តីសន្និដ្ឋាន នេះ។

៨. ទីមួយវគ្គដកស្រង់ខ្លីៗដែលបានលើកឡើងដោយមេធាវីការពារក្តី មិនមែនជាការកំណត់តាមផ្លូវតុលាការទៅតាមបញ្ហាពិតប្រាកដទាក់ទងនឹង នួន ជា ឬតួនាទីរបស់គាត់ឡើយ។ ហេតុនេះឧទាហរណ៍ដូចជា ក្នុងនោះបាននិយាយថា "*តាមការផ្តល់សក្ខីកម្មរបស់គាត់*ថា ជនជាប់ចោទបានទទួលការណែនាំពី...នួន ជា[35] ហើយ "*ជនជាប់ចោទបានបញ្ជាក់ថា...*គាត់បានរាយការណ៍ទៅឲ្យ នួន ជា"[36] (*ការសង្កត់ពាក្យត្រូវបានបញ្ជាក់ដោយអក្សរទ្រេត*)។ នៅក្នុងករណីទាំងនេះ គឺអង្គជំនុំជម្រះសាលាដំបូងគ្រាន់តែថា តាមឡើងវិញម្តងទៀតជាក់ស្តែងតាមអ្វីដែល ឌុច បាននិយាយតែប៉ុណ្ណោះ ហើយគឺមិនមែន ជាការផ្តល់ការយល់ព្រមទៅលើខ្លឹមសារនៃចម្លើយ ដោយចាត់ទុកថាជាការរកឃើញជាស្ថាពរអំពីតួនាទីរបស់ នួន ជា នោះឡើយ ។ ករណីបើសិនជាចម្លើយដែលគ្មានសុពលភាពទាំងត្រូវបានធ្វើឡើងនៅក្នុងកថាខណ្ឌទី៨៥និង៩៥នោះ គឺចម្លើយទាំងនេះត្រូវបានចាត់ចូលនៅក្នុងប្រភេទនៃ "ការលើកឡើងយោងដោយមានការប្រយ័ត្ន...ដែលដើម្បីមូលហេតុតែមួយគត់គឺដើម្បីផ្តល់ជូនអំពីប្រវត្តិសាវតារដើមតែប៉ុណ្ណោះ" ដូចគ្នានឹងការលើកឡើងដើម្បីយោងនៅក្នុងករណីរឿងក្តីរបស់ *Karadzić* ដែរ[37] ។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា សូមជូនសេចក្តីសន្និដ្ឋានថា ការលើកឡើងយោងទាំងនេះ គឺមិនមែនជាការកំណត់ទុកជាមុនណាមួយអំពីតួនាទីរបស់ នួន ជា ឬតាមពិតទៅ តួនាទីរបស់ជនជាប់ចោទណាម្នាក់ផ្សេងទៀតក៏ដោយនៅក្នុងករណីនេះ។

៩. ទីពីរ ការរកឃើញថា ជនជាប់ចោទបានកាន់កាប់មុខតំណែងជាក់លាក់មួយចំនួនក្នុងរបបនេះ ទោះបី "លក្ខខណ្ឌតម្រូវគ្រប់សព្វ" អំពីបទឧក្រិដ្ឋខុសៗគ្នាដែលត្រូវបានគេទទួលយកតាមការកំណត់យ៉ាងណាក្តី ក៏វាមិនគ្រប់គ្រាន់ដើម្បីកំណត់ជាមុនពីពិរុទ្ធភាពរបស់ជនជាប់ចោទដែរ។ ការអះអាងនេះបង្កប់នូវពិរុទ្ធភាពចំពោះការរៀបចំ ឬការប្រព្រឹត្តទៅ ដែលជាការជំទាស់ដាច់ខាតទៅនឹងគោលការណ៍នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គល។ ដើម្បីកំណត់អំពីការទទួលខុសត្រូវផ្នែក

[35] ករណីរឿងរបស់ ឌុច, កថាខណ្ឌទី៩០។

[36] ករណីរឿងរបស់ ឌុច, កថាខណ្ឌទី១៣១។

[37] ករណីរឿងក្តីរបស់ *Karadzić* , កថាខណ្ឌទី២២។

ព្រហ្មទណ្ឌរបស់បុគ្គល ទោះជាការទទួលខុសត្រូវតាមរយៈការបញ្ជា ការទទួលខុសត្រូវរបស់មេបញ្ជាការ ឬការទទួលខុសត្រូវរបស់ថ្នាក់លើ ឬសហកម្មឧក្រិដ្ឋកម្មរួមក្តី ជាការចាំបាច់ដែលគេត្រូវពិនិត្យឱ្យបានលម្អិតអំពី *បំណងឧក្រិដ្ឋ* របស់ជនជាប់ចោទផ្សេងៗគ្នា ដោយគិតអំពីចេតនា[38] ឬការដឹងឮ[39]របស់ពួកគេ *ក្នុងចំណោមកត្តាផ្សេងៗទៀត*។ ការណ៍នេះគ្មានអ្វីត្រូវពិភាក្សាទេ កុំថាឡើយដល់ការរកឃើញ ទាក់ទងនឹង*បំណងឧក្រិដ្ឋ* របស់ជនជាប់ចោទនៅក្នុងសាលក្រមរបស់ *ឌុច* និងថាបើដូច្នេះ ទោះបីជាការរកឃើញទាំងអស់បូកបញ្ចូលគ្នាក៏ដោយ ក៏គេមិនអាចនិយាយថា ចៅក្រមបានកំណត់ជាមុននូវពិរុទ្ធភាពរបស់ជនជាប់ចោទឡើយ។ *ពិរុទ្ធ* ត្រូវបានលើកឡើងតែអំពីអ្វីដែលទាក់ទងក្នុងករណី *ឌុច* ប៉ុណ្ណោះ មិនទាក់ទងនឹងជនជាប់ចោទទេ។

១០. ទីបី សេចក្តីយោងទាំងប៉ុន្មានអំពីតួនាទីរបស់ជនជាប់ចោទក្នុងករណី *ឌុច* គឺគ្រាន់តែដើម្បីគាំទ្រ ឬជាថែដន្យ ចំពោះការរកឃើញសំខាន់ៗនៃពិរុទ្ធភាពរបស់ *ឌុច* ចំពោះឧក្រិដ្ឋកម្មដែលគាត់ត្រូវបានចោទប្រកាន់តែប៉ុណ្ណោះ ។ បើដូច្នេះសេចក្តីថ្លែងទាំងនេះមិនមែនជាកម្មវត្ថុនៃបទដ្ឋានព្រហ្មទណ្ឌក្នុងការបង្ហាញភស្តុតាងឱ្យ“ហួសពីវិមតិសង្ស័យ”[40]ទេ ដែលដូចបានឆ្លុះបញ្ចាំងនៅក្នុងភាសានៃឯកសារសម្រង់ពីបញ្ហានេះ និងថាបើដូច្នេះ មិនអាចកំណត់បានអំពីការធ្វើឱ្យប្រាកដខ្លួននៃភាពលំអៀងបានឡើយ។ យុត្តិសាស្ត្រអន្តរជាតិសម្រេចថា ទោះបីពិរុទ្ធភាពរបស់ជនជាប់ចោទ នៅជាចំណោទនៅក្នុងសេចក្តីសម្រេចពីមុនក៏ដោយ ក៏ការណ៍នេះមិនអាចកំណត់បានអំពីពិរុទ្ធភាពដែរ ប្រសិនបើសេចក្តីសម្រេចពីមុននោះតម្រូវឱ្យមានបទដ្ឋាននៃការបង្ហាញភស្តុតាងទាបជាង[41]។ ដូច្នេះ នៅក្នុងករណី *Ntawukulilyayo* តុលាការ ICTR បានរកឃើញថា:

> ...ការប្រកាសរបស់តុលាការឧទ្ធរណ៍អំពីភាពសមហេតុសមផល នៃការរកឃើញដែលថា Kalimanzira បានដឹងថា ការសន្យាផ្តល់ជម្រកស្នាក់នៅសុវត្ថិភាពរបស់ Ntawukulilyayo គឺជាការខុស មិនមែនរួមបង្កើតបានជាសេចក្តីសម្រេចណាមួយអំពីពិរុទ្ធភាពរបស់ Ntawukulilyayo ឡើយ... ហើយការអះអាងរបស់គាត់ដែលថា គាត់ត្រូវបានរកឃើញថាជា សហចារីនៅក្នុងករណី

---

[38] *ឌុច*, កថាខ័ណ្ឌទី៥០៩ ។

[39] *ឌុច*, កថាខ័ណ្ឌទី៥០៩ ។

[40] *ឌុច*, កថាខ័ណ្ឌទី៤៤ និង៤៥ ។

[41] *Hauschildt ទល់នឹងប្រទេសដាណឺម៉ាក*, តុលាការសិទ្ធិមនុស្សអឺរ៉ុប លេខ 10486/83, សាលក្រម ចុះថ្ងៃទី២៤ ឧសភា ១៩៨៩, កថាខ័ណ្ឌទី៥០ ។

របស់ Kalimanzira គឺជាការកំណត់ចរិកលក្ខណៈមិនត្រឹមត្រូវ[42]។ នេះជាករណីដែលគ្មានការប្រាកដឡើងនៃភាពលំអៀង។ ករណីផ្សេងៗទៀត ដូចជាករណី *Karadzić*[43] និង *Galić*[44] ជាដើម បានពង្រឹងបន្ថែមទៀតដល់គោលការណ៍នេះ។ ស្រដៀងគ្នានេះដែរ ចំពោះករណីនេះវិញ វាគឺជាការកំណត់ចរិកលក្ខណៈមិនត្រឹមត្រូវសម្រាប់មេធាវីការពារក្តី ក្នុងការតវ៉ាថា សាលក្រម *ឌុច* បានកំណត់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទទាំងនេះ។

១១. សហព្រះរាជអាជ្ញាកត់សំគាល់ថា វាជាឱកាសដ៏កម្រមួយដែលថា ការប្រាកដឡើងនៃភាពលំអៀងត្រូវបានរកឃើញនៅក្នុងមូលដ្ឋាននៃសេចក្តីសម្រេចរបស់តុលាការពីមុន ជាពិសេសនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ: គ្មានករណីព្រហ្មទណ្ឌអន្តរជាតិណាមួយដែលបានលើកយោងដោយភាគីនានា បង្ហាញឱ្យឃើញយ៉ាងដូច្នេះឡើយ។ គេមានករណីយុត្តិសាស្ត្រច្បាស់លាស់ និងស៊ីសង្វាក់គ្នា ដើម្បីបង្ហាញឱ្យឃើញពីកំរិតនៃភាពត្រួតគ្នារវាងករណីនានា ដែលកើតចេញពីប្រភេទនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងថាបើដូច្នេះ មិនអាចបង្កើតបានជាមូលដ្ឋានសម្រាប់ការប្តឹងជំទាស់ចៅក្រមបានឡើយ[45]។ ករណីពីរដែលបានលើកយោង ដែលករណីនោះត្រូវបានសម្រេចថា មានភាពប្រាកដឡើងនៃភាពលំអៀងដូច្នេះមែន គឺមានដើមកំណើតចេញពីតុលាការសិទ្ធិមនុស្សអឺរ៉ុប ហើយដែលសេចក្តីសម្រេចពីមុនបានរកឃើញ*យ៉ាងច្បាស់* ថាជនជាប់ចោទបានជួយក្នុងឧក្រិដ្ឋកម្ម[46] និងដែលតម្រូវឱ្យចៅក្រមកំណត់អំពីពិរុទ្ធភាពរបស់អ្នកដាក់ពាក្យសុំតាំងពីមុន ដើម្បីឱ្យ "ភាពច្បាស់លាស់មានកំរិតខ្ពស់បំផុត"[47]។ ចំណែកករណីនៅទីនេះវិញ មិនជាប់ទាក់ទងនឹងកាលៈទេសៈពិសេសដូច្នេះទេ និងបើតាមមូលហេតុដូចបានរៀបរាប់ខាងលើ គឺវាមានលក្ខណៈស្រដៀងគ្នាទៅនឹងករណី *Poppe ទល់នឹង ប្រទេសហូឡង់* ដែលក្នុងករណីនេះ តុលាការសិទ្ធិមនុស្សអឺរ៉ុប បានសម្រេចថា:

---

[42] *Ntawukulilyayo*, កថាខ័ណ្ឌទី១៨ ។

[43] *Karadzić*, កថាខ័ណ្ឌទី ២២ និង២៤ ។

[44] *Galić*, កថាខ័ណ្ឌទី៤២ ។

[45] សូមអាន *ក្នុងចំណោមករណីផ្សេងៗទៀត* Kordić និង Čerkez, ទំព័រ៣, Ntawukulilyayo, កថាខ័ណ្ឌទី១២, *រដ្ឋអាជ្ញា ទល់នឹង* Krajisnik, IT-00-39-PT, សេចក្តីសម្រេចដោយចៅក្រមតែមួយរូប លើពាក្យសុំរបស់មេធាវីការពារក្តី សុំឱ្យដកចៅក្រមមួយរូបចេញពីសវនាការ, ថ្ងៃទី២២ មករា ២០០៣, កថាខ័ណ្ឌទី១៥ និង Brđanin និង Talić, កថាខ័ណ្ឌទី១៧ ។

[46] *Ferrantelli និង Santangelo ទល់នឹងប្រទេសអ៊ីតាលី*, តុលាការសិទ្ធិមនុស្សអឺរ៉ុប ពាក្យសុំលេខ 48/1995 & 554/640, សាលក្រមចុះថ្ងៃទី៧ សីហា ១៩៩៦, កថាខ័ណ្ឌទី៥៩ ។

[47] *Hauschildt*, កថាខ័ណ្ឌទី៥២ ។

... នៅក្នុងសាលក្រមទាំងពីរ ឈ្មោះរបស់អ្នកដាក់ពាក្យសុំ និងឈ្មោះអ្នកដទៃទៀតដែលមាននៅក្នុងឯកសារសម្រង់ គឺគ្រាន់តែដើម្បីបង្ហាញ និងបញ្ជាក់បំភ្លឺអំពីតួនាទីនាំមុខដែលបានធ្វើក្នុងអង្គការឧក្រិដ្ឋកម្មដោយទណ្ឌិតតែប៉ុណ្ណោះ... ថាតើការពាក់ព័ន្ធរបស់អ្នកដាក់ពាក្យសុំជាមួយ C3 និង D បានបំពេញទៅតាមលក្ខខណ្ឌតម្រូវចាំបាច់ដែលពាក់ព័ន្ធទាំងអស់ដែរឬទេ ដើម្បីបង្កើតបានជាបទល្មើសព្រហ្មទណ្ឌណាមួយ និងថាបើមានមែន តើគេបានលើកយកមកដោះស្រាយ កំណត់ ឬវាយតម្លៃអំពីគោលការណ៍ហួសពីវិមតិសង្ស័យ ថាតើអ្នកដាក់ពាក្យសុំមានពិរុទ្ធចំពោះការប្រព្រឹត្តបទល្មើសដែរឬអត់។ អាស្រ័យហេតុនេះ គេមិនអាចនិយាយបានថា ការភ័យខ្លាចចំពោះភាពលំអៀងណាមួយ ... ដែលអ្នកដាក់ពាក្យសុំអាចនឹងមាន គឺជាយុត្តិកម្មសត្យានុម័តបានឡើយ[48]។

១២. សហព្រះរាជអាជ្ញាសន្និដ្ឋានថា ស្រដៀងនឹងករណី *Poppe* ដែរ ការរកឃើញ និងឯកសារសម្រង់ទាក់ទងនឹងពាក្យបណ្តឹង ដែលបានធ្វើឡើងដោយជនជាប់ចោទនៅក្នុងករណីរឿងនេះ មិនបានរំលោភលើសច្ចធារណ៍និរទោសដែលពួកគេសមនឹងទទួលបាននោះទេ។ នេះជាករណីចំពោះសច្ចធារណ៍និរទោសដែលចៅក្រមមានគឺ *"សមត្ថភាពដើម្បីដាក់ចេញភស្តុតាងប្រកបដោយហេតុផល ជាជាងភស្តុតាងដែលបានបង្ហាញនៅពេលសវនាការនៅក្នុងការសម្រេចចេញសាលក្រម"*[49] ដែលត្រូវតែមានអនុភាពលប់ ដែលថាការប្រាកដខ្លួននៃភាពលំអៀងមិនត្រូវបានកំណត់ឱ្យឃើញទេ ហើយចៅក្រមត្រូវតែបានអនុញ្ញាតផ្តល់នូវឱកាសឱ្យធ្វើ "ការពិចារណាជាថ្មី" លើបញ្ហានេះ[50]។

---

[48] *Poppe ទល់នឹងប្រទេសហូឡង់*, កថាខ័ណ្ឌទី២៨ ។

[49] *Galić*, កថាខ័ណ្ឌទី៤៤ ។

[50] *Thomann ទល់នឹងប្រទេសស្វីស*, តុលាការសិទ្ធិមនុស្សអឺរ៉ុប, សាលក្រម ចុះថ្ងៃទី១០ មិថុនា ១៩៩៦, កថាខ័ណ្ឌទី៣៥ ។

## **សំណើ**

១៣. ដូចមូលហេតុរៀបរាប់ខាងលើ សហព្រះរាជអាជ្ញា សន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង គួរតែច្រានចោលពាក្យសុំនេះទាំងមូល, បដិសេធសំណើរបស់ជនជាប់ចោទដែលប្តឹងជំទាស់ដល់នូវ… 

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ | **លោកយ៉េត ចរិយា**<br>សហព្រះរាជអាជ្ញារង | ភ្នំពេញ | |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |